**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

លេខ: ០១០/ប្រ.ក..អ.ជ.ប.គ.ញ
០៩

# ប្រកាស
## ស្តីពី
## តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ
## នាយកដ្ឋានអនុវត្តច្បាប់ នៃអគ្គលេខាធិការដ្ឋាន
## នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៩០៨/១០៥៤ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខនស/រកត/០៩៩៥/៦៥/ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញ ព្រះរាជក្រឹត្យលេខនស/រកត/០៦០៦/២៧៤/ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ បក ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- តាមសំណើរបស់អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ស ម្រេ ច

**ប្រការ ១** : ប្រកាសនេះកំណត់ តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ របស់នាយកដ្ឋានអនុវត្តច្បាប់ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

### អំពីតួនាទី និង ភារកិច្ចរបស់នាយកដ្ឋាន

**ប្រការ ២ :** នាយកដ្ឋានអនុវត្តច្បាប់មានតួនាទីធ្វើជាសេនាធិការ អោយអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការប្រមូលពត៌មាន និង ក្នុងការសំរបសំរួលប្រតិបត្តិការប្រឆាំងនឹងការជាំជុះ ការផលិត និង ការធ្វើជំនួញគ្រឿងញៀន ជាមួយអង្គភាពអនុវត្តច្បាប់នានា ដើម្បីធានាអោយបាននូវប្រសិទ្ធិភាពនូវការបង្ក្រាបគ្រឿងញៀននៅកម្ពុជា ។ ដើម្បីបំពេញតួនាទីខាងលើអោយទទួលបានជោគជ័យ នាយកដ្ឋានអនុវត្តច្បាប់ត្រូវមានភារកិច្ចសំខាន់ៗ ដូចតទៅៈ

១. ស្រាវជ្រាវ និងប្រមូលពត៌មានពាក់ព័ន្ធនឹងគ្រឿងញៀនដោយសហការជាមួយ ក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២. ត្រួតពិនិត្យ និង បង្ក្រាបការជាំជុះ ការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ការឆ្លងកាត់ ឬ ការសុំចតគ្រឿងញៀន ឱសថដែលមានសារធាតុញៀន និង ថ្នាំស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដោយសហការជាមួយនឹងក្រសួង-ស្ថាប័ន និង អង្គការពាក់ព័ន្ធដទៃទៀត ។

៣. តាមដាន និង អនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង សាលក្រមតុលាការដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ។

៤. រៀបចំលិខិតបទដ្ឋានសុវត្ថិភាពស្តីពីការវេចខ្ចប់ ការប្រគល់ទទួល ការរក្សារទុក និង ការកំទេចចោលគ្រឿងញៀនដែលចាប់បាន ដោយសហការជាមួយក្រសួង-ស្ថាប័ន និង អង្គការពាក់ព័ន្ធដទៃទៀត ។

៥. រៀបចំ និងគ្រប់គ្រងមជ្ឈមណ្ឌលពត៌មានគ្រឿងញៀន ។

៦. សំរបសំរួល និង ចូលរួមក្នុងការបង្កើត និងអនុវត្តនូវកម្មវិធីប្រឆាំងនឹងការសំអាតប្រាក់ដែលបានមកពីជំនួញគ្រឿងញៀនខុសច្បាប់ ។

**ប្រការ ៣ :** នាយកដ្ឋានអនុវត្តច្បាប់ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវបានដឹកនាំ និង គ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធានជាជំនួយការ ។ ប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយអនុក្រឹត តាមសំណើរបស់អគ្គលេខាធិការ ដោយមានការយល់ព្រមពីប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ពីក្នុងចំណោមមន្ត្រីដែលមានឋានន្តរសក្តិចាប់ពីថ្នាក់វរៈមន្ត្រី នៃក្របខ័ណ្ឌរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬនាយនគរបាលជាតិជាន់ខ្ពស់ ចាប់ពីថ្នាក់ឧត្តមសេនីយ៍ត្រីឡើង ។

**ប្រការ ៤ :** អនុប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយប្រកាសអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមសំណើប្រធាននាយកដ្ឋានអនុវត្តច្បាប់ ដោយមានការឯកភាពពីអគ្គលេខាធិការ ក្នុងចំណោមមន្ត្រី

ដែលមានឋានន្តរសក្តិចាប់ពីអនុមន្ត្រី នៃក្របខ័ណ្ឌរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬនាយនគរបាលជាតិជាន់ខ្ពស់ ចាប់ពីថ្នាក់វរសេនីយ៍ឯកឡើង ។

**ប្រការ ៥ :** ប្រធាននាយកដ្ឋាន អនុវត្តច្បាប់ ត្រូវបំពេញភារកិច្ចដូចខាងក្រោម :

- ទទួលខុសត្រូវលើការងារដំណើរការ និងគ្រប់គ្រងនាយកដ្ឋាន និងទទួលខុសត្រូវលើកិច្ចការនានាចំពោះមុខអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អ.ជ.ប.គ.ញ) ។
- រាយការណ៍ជូន អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ពីកិច្ចការនានា ដែលទាក់ទងទៅនឹងការងារដំណើរការ និង គ្រប់គ្រងនាយកដ្ឋាន ។
- លើកសំណើអំពីការតែងតាំង ការតំឡើងឋានន្តរសក្តិ ឬ ផ្ទេរមន្ត្រីរាជការក្រោមឱវាទរបស់នាយកដ្ឋាន ។
- ចុះហត្ថលេខាលើគ្រប់ឯកសារ ដែលទាក់ទងទៅនឹងការងាររបស់នាយកដ្ឋាន
- មានសិទ្ធិធ្វើប្រតិភូកម្មអំណាចចុះហត្ថលេខា ដែលទាក់ទងកិច្ចការនាយកដ្ឋានដល់អនុប្រធាននាយកដ្ឋាន។

**ប្រការ ៦ :** អនុប្រធាននាយកដ្ឋាន អនុវត្តច្បាប់ ត្រូវបំពេញភារកិច្ចដូចខាងក្រោម :

- ទទួលខុសត្រូវចំពោះមុខប្រធាននាយកដ្ឋានចំពោះកិច្ចការនានា ដែលប្រគល់អោយ
- ត្រូវរាយការណ៍ជូនប្រធាននាយកដ្ឋានអំពីកិច្ចការនានា ដែលស្ថិតក្រោមការទទួលខុសត្រូវឬសមត្ថកិច្ចរបស់ខ្លួន
- មានសិទ្ធិចុះហត្ថលេខាលើឯកសារ ដែលទាក់ទងនឹងកិច្ចការរដ្ឋបាលក្រោមការធ្វើប្រតិភូកម្មពីប្រធាននាយកដ្ឋាន ។

## អំពីរចនាសម្ព័ន្ធរបស់នាយកដ្ឋាន

**ប្រការ ៧ :** ដើម្បីធានាអោយនាយកដ្ឋានមានដំណើរការល្អប្រសើរ និងមានប្រសិទ្ធិភាព ស្របតាមតួនាទី និងភារកិច្ចខាងលើ នាយកដ្ឋានអនុវត្តច្បាប់ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវមានរចនាសម្ព័ន្ធដូចតទៅ:

១. ការិយាល័យស៊ើបការណ៍

២. ការិយាល័យអនុវត្តច្បាប់

៣. ការិយាល័យត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន

៤. ការិយាល័យប្រឆាំងដំណាំគ្រឿងញៀនខុសច្បាប់

៥. ការិយាល័យបណ្តុះបណ្តាល និង បច្ចេកទេស និង

៦. មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន

ការិយាល័យ និង មជ្ឈមណ្ឌល នីមួយៗ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធាន អនុប្រធានមួចំនួនតាមការចាំបាច់ ។ ប្រធានការិយាល័យ និងប្រធានមជ្ឈមណ្ឌលត្រូវតែងតាំងដោយប្រកាស របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមសំណើរបស់ប្រធាននាយកដ្ឋានអនុវត្តច្បាប់ដោយមានការឯកភាពពីអគ្គលេខាធិការ ពីក្នុងចំណោមមន្ត្រីដែលមានឋានន្តរ-សក្តិចាប់ពីនាយក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ឬនាយនគរបាលជាតិចាប់ពីថ្នាក់វរសេនីយ៍ទោ ឡើងទៅ ។

អនុប្រធានការិយាល័យ និង អនុប្រធានមជ្ឈមណ្ឌល ត្រូវតែងតាំងដោយប្រកាសរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមសំណើរបស់ប្រធាននាយកដ្ឋានអនុវត្តច្បាប់ ដោយមានការឯកភាពពីអគ្គលេខាធិការ ពីក្នុងចំណោមមន្ត្រីដែលមានឋានន្តរសក្តិចាប់ពីក្រមការដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ឬ នាយនគរបាលជាតិចាប់ពីថ្នាក់វរសេនីយ៍ត្រីឡើងទៅ ។

អង្គការលេខរបស់នាយកដ្ឋានអនុវត្តច្បាប់ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានចែងក្នុងឧបសម្ព័ន្ធ នៃប្រកាសនេះ ។

## អំពីភារកិច្ចរបស់ការិយាល័យ និងមជ្ឈមណ្ឌល

**ប្រការ ៨ : ការិយាល័យស៊ើបការណ៍មានភារកិច្ចដូចតទៅៈ**

- រៀបចំ និង បង្កើតអោយមានបណ្តាញប្រមូល និងផ្តល់ពត៌មានគ្រប់ប្រភេទ ដើម្បីបំរើអោយការងារប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន ជាទូទៅ ។
- ធ្វើការវិភាគពត៌មាន និងចំណាត់ថ្នាក់ពត៌មានគ្រឿងញៀន
- សំរបសំរួលសកម្មភាពប្រមូលពត៌មានគ្រឿងញៀនជាមួយអង្គភាពអនុវត្តច្បាប់ ដែលពាក់ព័ន្ធទាំងក្នុង និង ក្រៅប្រទេស ។
- ធានាការសំងាត់នៃពត៌មានដែលទទួលបាន និង រៀបចំរបាយការណ៍ពត៌មានសំងាត់ពាក់ព័ន្ធនឹងករណីគ្រឿងញៀន ។
- រក្សាទុកទិន្នន័យពត៌មាននៃការអនុវត្តច្បាប់គ្រឿងញៀន ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានប្រគល់អោយ ។

**ប្រការ ៩ : ការិយាល័យអនុវត្តច្បាប់ មានភារកិច្ចដូចតទៅៈ**

- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីធ្វើជាសេនាធិការក្នុងការងាររៀបចំលិខិតបទដ្ឋានច្បាប់នានា ដើម្បីអោយដំណើរការនៃការអនុវត្តច្បាប់គ្រឿងញៀន នៅកម្ពុជា មានប្រសិទ្ធិភាព ។
- ចូលរួមជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការអនុវត្តនូវច្បាប់ អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ នានា ស្តីពីគ្រឿងញៀន ។

- ចូលរួមក្នុងការអនុវត្តកម្មវិធីប្រមូលអ្នកញៀនគ្រឿងញៀន ចូលក្នុងមជ្ឈមណ្ឌលព្យាបាល និង ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីធ្វើសកម្មភាពប្រឆាំងនឹងការសំអាតប្រាក់ដែលបានមកពី ជំនួញគ្រឿងញៀនខុសច្បាប់ ។
- ចូលរួមស៊ើបអង្កេតករណីគ្រឿងញៀន ជាមួយស្ថាប័នមានសមត្ថកិច្ច ពាក់ព័ន្ធ។
- សហការជាមួយនគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ដើម្បីអនុវត្តច្បាប់គ្រឿងញៀន និង សាលក្រមរបស់តុលាការ ពាក់ព័ន្ធនឹងករណីគ្រឿងញៀន ។
- តាមដាន និង ប្រមូលពតិមានពាក់ព័ន្ធនឹងសំណុំរឿងគ្រឿងញៀនដែលបានបញ្ជូនទៅតុលាការ និង តាមដានអំពីដំណើរការនៃការអនុវត្តនីតិវិធីរបស់តុលាការ ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ។

**ប្រការ១០ : ការិយាល័យត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន មានភារកិច្ចដូចតទៅៈ**

- សហប្រតិបត្តិការ និង សំរបសំរួលវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀនរវាងខេត្ត-ក្រុង ជាប់ព្រំដែន និង ប្រទេសជិតខាង កម្ពុជា ។
- សំរបសំរួល និង សហការជាមួយអង្គភាពពាក់ព័ន្ធ និង ខេត្ត-ក្រុង ជាប់ព្រំដែនដើម្បីរៀបចំកម្មវិធីជួបប្រជុំនានា ជាមួយប្រទេសជិតខាងពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- រៀបចំ និង បង្កើតអោយមានបណ្តាញការងារជាមួយអង្គភាពអនុវត្តច្បាប់នានានៅតាមតំបន់ព្រំដែននៃប្រទេស ពិសេស នៅតាមចំណុចច្រកទ្វារព្រំដែននានា ទាំងផ្លូវគោក ផ្លូវទឹក និង អាកាស ។
- រៀបចំ និងគ្រប់គ្រងការងារការិយាល័យទំនាក់ទំនងព្រំដែនផ្នែកគ្រឿងញៀន (BLO) នៅទូទាំងប្រទេស ។
- រៀបចំ និង បង្កើតអោយមានបណ្តាញការងារ ជាមួយអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធនៅតាមប៉ុស្តិ៍ប្រៃសណីយ៍ ដែលមានសេវាកម្មបំរើសេវាផ្ញើជាលក្ខណៈអន្តរជាតិ នានា ។
- ធ្វើការត្រួតពិនិត្យគ្រឿងញៀន ឱសថដែលមានសារធាតុញៀនគ្រឿងញៀន ដែលបាននាំចូល និង នាំចេញ នៅចំណុចច្រកទ្វារព្រំដែន ដោយសហការជាមួយក្រសួង និង អង្គភាពពាក់ព័ន្ធដទៃទៀត ។
- សហការជាមួយអង្គភាពពាក់ព័ន្ធនានាដែលប្រចាំការនៅច្រកទ្វាព្រំដែន ដើម្បីធ្វើការត្រួតពិនិត្យទៅលើមនុស្ស សត្វ សំភារៈ និង ការដឹកជញ្ជូននានាដែលសង្ស័យថាមានការពាក់ព័ន្ធនឹងគ្រឿងញៀន ។

- ធ្វើរបាយការណ៍អំពីសភាពការណ៍គ្រឿងញៀននៅតាមតំបន់ព្រំដែនក្នុងប្រទេស និង នៅក្រៅប្រទេស ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានប្រគល់អោយ ។

**ប្រការ១១ : ការិយាល័យប្រឆាំងដំណាំគ្រឿងញៀនខុសច្បាប់ មានភារកិច្ចដូចតទៅ:**

- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំ និង បង្កើតប្រព័ន្ធតាមដាន និង ឃ្លាំមើល ការដាំដុះដំណាំគ្រឿងញៀនខុសច្បាប់នៅកម្ពុជា។
- ចុះធ្វើការស្រាវជ្រាវ និង ប្រមូលពត៌មានតាមមូលដ្ឋាន អំពីការវិវត្តន៍នៃសភាពការណ៍ដាំដុះគ្រឿងញៀន ខុសច្បាប់នៅកម្ពុជា ។
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយដល់ប្រជាជនអោយយល់ពីទោសបញ្ញត្តិនៃការដាំដុះដំណាំគ្រឿងញៀនខុសច្បាប់ ។
- ចូលរួមជាមួយអង្គភាព ស្ថាប័នពាក់ព័ន្ធ និងអង្គការជាតិ និង អន្តរជាតិ នានាក្នុងការអនុវត្តកម្មវិធីដំណាំជំនួស និងក្នុងការបំផុសប្រជាជនអោយចូលរួមក្នុងការប្រឆាំងនឹងការដាំដុះដំណាំគ្រឿងញៀនខុសច្បាប់ ។
- សហការជាមួយអង្គភាពអនុវត្តច្បាប់នានា ក្នុងការបំផ្លាញដំណាំគ្រឿងញៀនខុសច្បាប់ ។
- ធ្វើរបាយការណ៍អំពីសភាពការណ៍វិវត្តន៍នៃដំណាំគ្រឿងញៀនខុសច្បាប់នៅកម្ពុជា ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ។

**ប្រការ១២ : ការិយាល័យបណ្តុះបណ្តាល និង បច្ចេកទេស មានភារកិច្ចដូចតទៅ:**

- សហការជាមួយអង្គការជាតិ និង អន្តរជាតិ ដើម្បីរៀបចំពង្រឹង ពង្រីកមជ្ឈមណ្ឌលបណ្តុះបណ្តាលការអនុវត្តច្បាប់គ្រឿងញៀន ដោយយកកុំព្យូទ័រធ្វើជាមូលដ្ឋាន (CBT) ដើម្បីលើកកំពស់ការយល់ដឹងរបស់មន្ត្រីអនុវត្តច្បាប់គ្រឿងញៀននៅកម្ពុជា ។
- គ្រប់គ្រង និង ផ្តល់ជំនួយបច្ចេកទេសដល់មជ្ឈមណ្ឌលបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រឿងញៀន ដោយ យកកុំព្យូទ័រជាមូលដ្ឋាន (CBT) នៅកន្លែងផ្សេងៗទៀតនៅកម្ពុជា ។
- សហការជាមួយអង្គភាព និង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំនីតិវិធីស្តីពីសុវត្ថិភាព នៃការទុកដាក់ និង កំទេចចោលគ្រឿងញៀនដែលចាប់បាន ។
- សហការជាមួយអង្គភាព និង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំនីតិវិធីនៃការធ្វើកោសល្យវិច្ច័យជំហានដំបូងលើគ្រឿងញៀនដែលរឹបអូសបាន ។
- ចូលរួមក្នុងការធ្វើកោសល្យវិច្ច័យជំហានដំបូងចំពោះបទល្មើសគ្រឿងញៀន ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ។

**ប្រការ១៣ ៖ មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន មានភារកិច្ចដូចតទៅ៖**

- ធ្វើជាមជ្ឈមណ្ឌលក្នុងការប្រមូល ចងក្រង វិភាគ និង រក្សាទុក នូវពត៌មានគ្រឿងញៀន គ្រប់ប្រភេទ សំដៅជំរុញអោយកម្ពុជាមានទិន្នន័យគ្រប់គ្រាន់ស្តីពីបញ្ហាគ្រឿងញៀន ។
- ជំរុញ លើកកំពស់ការអនុវត្តការងារប្រមូលទិន្នន័យពត៌មានគ្រឿងញៀន ដោយប្រើប្រាស់បច្ចេកទេសពត៌មានវិទ្យា អោយបានសមស្របដល់បណ្តាគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ សំដៅធ្វើអោយទិន្នន័យដែលទទួលបានមានលក្ខណៈវិទ្យាសាស្ត្រ និងទាន់ពេលវេលា ។
- ជួយដល់នាយកដ្ឋាន ក្នុងការវាយតំលៃសភាពការណ៍គ្រឿងញៀននៅក្នុង និងក្រៅប្រទេសដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ជួយនាយកដ្ឋានក្នុងការរៀបចំជូនអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការចេញផ្សាយពត៌មានគ្រឿងញៀននានា ដែលទទួលបានតាមបញ្ជារបស់អគ្គលេខាធិការ ។
- ជួយនាយកដ្ឋានក្នុងការ គ្រប់គ្រងបច្ចេកទេស លើការដាក់អោយប្រើប្រាស់ប្រព័ន្ធបញ្ជូន និងផ្ញើសារតាមប្រព័ន្ធអេឡិកត្រូនិក(Internetនិង Emial) របស់អគ្គលេខាធិការដ្ឋានអ.ជ.ប.គ.ញ ។
- ជួយនាយកដ្ឋានក្នុងការរៀបចំ និង គ្រប់គ្រងវែបសាយរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ជួយនាយកដ្ឋានក្នុងការ សហការជាមួយអ្នកជំនាញការ និងអង្គការពាក់ព័ន្ធនានាក្នុងការធ្វើអង្កេតរកទិន្នន័យអ្នកប្រើប្រាស់គ្រឿងញៀន និង ទិន្នន័យនានាពាក់ព័ន្ធនឹងគ្រឿងញៀន ព្រមទាំងរៀបចំនីតិវិធីក្នុងការប្រមូល វិភាគ ចងក្រង និង រក្សាទុកទិន្នន័យពត៌មានគ្រឿងញៀន ។
- ជួយនាយកដ្ឋានក្នុងការរៀបចំរបាយការណ៍ស្តីពីទិន្នន័យពត៌មានគ្រឿងញៀនខុសច្បាប់ប្រចាំឆ្នាំស្តីពីការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ជួយនាយកដ្ឋានក្នុងការរៀបចំការងារប្រមូលទិន្នន័យពត៌មានគ្រឿងញៀន នៅគ្រប់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង គ្រប់ស្ថាប័នអនុវត្តច្បាប់ នៅគ្រប់មណ្ឌលអប់រំ និងបន្សាបជាតិញៀន របស់រដ្ឋ ឯកជន និងអង្គការសង្គមស៊ីវិលនានា និង ទីកន្លែងនានាដែលពាក់ព័ន្ធក្នុងការផ្តល់សេវាកម្មជួយដល់អ្នកញៀនគ្រឿងញៀន ។
- ក្រៅពីការងារខាងលើនេះ មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន មានភារកិច្ចក្នុងការជួយប្រធាននាយកដ្ឋានអនុវត្តច្បាប់ លើការងារគ្រប់គ្រងបុគ្គលិក ថវិកា សំភារៈ និងការងាររដ្ឋបាលក្នុងនាយកដ្ឋានអនុវត្តច្បាប់ ព្រមទាំងជាជំនួយបច្ចេកទេសក្នុងការគ្រប់គ្រងមជ្ឈមណ្ឌល CBT របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

**មាត្រា ១៤:** រាល់ប្រកាស ដីកា និងលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៥:** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋាន ភស្តុភារ និង ហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង និងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១១ ខែ មិថុនា ឆ្នាំ ២០០៩*

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជា**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

ស ខេង

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

( ***ដើម្បីជូនជ្រាប*** ) ។

- ដូចប្រការ១៥ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធ

# នាយកដ្ឋាន អនុវត្តច្បាប់

